**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ០៣៤ ជនស.ឈឃ

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែពិសាខ ឆ្នាំវក ព.ស. ២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា គ.ស. ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួងនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០១៣/១០៩៩ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៤/០៨១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងឯកឧត្តម សារុន ឫទ្ធា ជាអនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៦/៣៨៤ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី គរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៦/៤៩៧ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការផ្ទេរឥស្សរជនចំនួន ០២ រូប ពីអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ មកជាអនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី គរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-

# សម្រេច

**ប្រការ ១** : ត្រូវបានបែងចែកភារកិច្ចជូនរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ សំដៅធានាការដឹកនាំ និងអនុវត្តកិច្ចការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចខាងក្រោម÷

**ក.<u>រដ្ឋមន្ត្រី</u>**

ឯកឧត្តម **ជា សុផារ៉ា** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទទួលបន្ទុកដឹកនាំការងាររួមរបស់ក្រសួង បញ្ជាដឹកនាំអនុវត្តរាល់គោលនយោបាយ យុទ្ធសាស្ត្រ និងសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ទទួលដឹកនាំផ្ទាល់ការងារដោះស្រាយទំនាស់ដីធ្លី ការងារបុគ្គលិក ការងារលទ្ធកម្ម ការងារអធិការកិច្ច និងការងារសវនកម្មផ្ទៃក្នុង។

**<u>ខ.រដ្ឋលេខាធិការ</u>**

១-ឯកឧត្តម **ឆាន់ សាផាន** រដ្ឋលេខាធិការ ទទួលបន្ទុកអចិន្ត្រៃយ៍ មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ÷

- ដោះស្រាយទំនាស់ដីធ្លី
- ទូទៅរបស់ក្រសួង
- អគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គនាយកដ្ឋានលំនៅឋាន
- ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)។

២-ឯកឧត្តម **លឹម ឆាន់** រដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ដោះស្រាយទំនាស់ដីធ្លី
- រៀបចំឯកសារឆ្លើយតបនឹងសំណួររបស់រដ្ឋសភានិងព្រឹទ្ធសភា
- ពាក់ព័ន្ធនឹងផ្នែកច្បាប់ នីតិកម្ម និងការងារអភិរក្សសុរិយោដី
- លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- ទំនាក់ទំនងជាមួយរដ្ឋសភា និងព្រឹទ្ធសភា និង
- ជាប្រធានក្រុមការងារអភិវឌ្ឍនិងផ្សព្វផ្សាយគោលនយោបាយ និងច្បាប់។

៣-លោកជំទាវ **អ៊ូ វ៉ាឌី** រដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ដោះស្រាយទំនាស់ដីធ្លី
- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- គោលនយោបាយដីធ្លី
- ការងារយេនឌ័រ និង
- បូកសរុប។

៤-ឯកឧត្តម **គឿង សុគណ្ឋ** រដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ដោះស្រាយទំនាស់ដីធ្លី
- អគ្គនាយកដ្ឋានសំណង់ និង
- គណៈស្ថាបត្យករកម្ពុជា ។

៥-ឯកឧត្តម **សរ សុវណ្ណ** រដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ដោះស្រាយទំនាស់ដីធ្លី
- រៀបចំឯកសារឆ្លើយតបនឹងសំណួររបស់រដ្ឋសភានិងព្រឹទ្ធសភា
- អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្រ្ត
- កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី
- ក្រុមការងារបច្ចេកទេសដីធ្លី (TWG-Land)
- កិច្ចការព្រំដែន
- ចុះបញ្ជីដីរដ្ឋ
- មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី និង
- ទំនាក់ទំនងសាធារណៈជាមួយប្រព័ន្ធឃោសនា និងកិច្ចការសហប្រតិបត្តិការអន្តរជាតិ។

៦-ឯកឧត្តម **ប៉ែន សុផល** រដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី លើការងារ÷

- ដោះស្រាយទំនាស់ដីធ្លី
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ និង
- គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

**គ.អនុរដ្ឋលេខាធិការ**

១- លោកជំទាវ **ឆិត្យ ច័ន្ទតារីន** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី គោលនយោបាយ និងយេនឌ័រ។

២-ឯកឧត្តម **ទេព ឆន** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាល ការងារសរុប និងផែនការ កិច្ចការវិនិយោគ និងជាតំណាងក្រសួងប្រចាំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៣-ឯកឧត្តម **សេង ថានី** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី អគ្គនាយកដ្ឋានលំនៅឋាន អភិវឌ្ឍន៍ស្ថាប័ន និងការងារបណ្តុះបណ្តាល ។

៤-ឯកឧត្តម **សារុន ឫទ្ធា** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី ពាក់ព័ន្ធកិច្ចការអាស៊ាន កិច្ចការអន្តរជាតិ គេហទំព័ររបស់ក្រសួង ទំព័របណ្តាញសង្គម Facebook ការងារពាក់ព័ន្ធនឹងស្ថាប័ននីតិប្បញ្ញត្តិជាមួយរដ្ឋសភា និងព្រឹទ្ធសភា។

៥-ឯកឧត្តម **ថេង ច័ន្ទសង្វារ** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី នីតិកម្ម ព័ត៌មាន និងជានាយកខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី។

៦-ឯកឧត្តម **ខិម សំអែល** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី រដ្ឋបាលទូទៅ ហិរញ្ញវត្ថុ និងតាមដានការអនុវត្តសេចក្តីសម្រេចរបស់ក្រសួង។

៧-ឯកឧត្តម **ប៊ិន សម្បត្តិថារ័ត្ន** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី រៀបចំដែនដី ការងារអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម។

៨-ឯកឧត្តម **ទេវ សុទ្ធទុធ** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី រៀបចំដែនដី អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម។

៩-ឯកឧត្តម **យស់ ឆោមណារ៉ាឌី** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី នគរូបនីយកម្ម និងការងារគណៈស្ថាបត្យករកម្ពុជា។

១០-ឯកឧត្តម **មាន ច័ន្ទវ៉ាន់នី** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី នគរូបនីយកម្ម និងការងារគណៈស្ថាបត្យករកម្ពុជា។

១១-ឯកឧត្តម **ខុច ធនធីតូ** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី ផែនការរៀបចំដែនដី និងសម្បទានដីសង្គមកិច្ច។

១២-ឯកឧត្តម **ធា ច័ន្ទលីដា** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានស្រាវជ្រាវបច្ចេកទេស និងនាយកដ្ឋានសំណង់នៃអគ្គនាយកដ្ឋានសំណង់ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យសំណង់។

១៣-ឯកឧត្តម **អ៊ឹម ចំរុង** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានស្រាវជ្រាវបច្ចេកទេស និងនាយកដ្ឋានសំណង់នៃអគ្គនាយកដ្ឋានសំណង់ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យសំណង់។

១៤-ឯកឧត្តម **កើត សារ៉េត** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានស្រាវជ្រាវបច្ចេកទេស និងនាយកដ្ឋានសំណង់នៃអគ្គនាយកដ្ឋានសំណង់ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យសំណង់។

១៥-ឯកឧត្តម **លាង មុនីរិទ្ធ** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានសិក្សាគម្រោងប្លង់នៃអគ្គនាយកដ្ឋានសំណង់ ការងារមន្ទីរពិសោធន៍សំណង់ ការងារប្រមូលផ្តុំទិន្នន័យសំណង់ និងតាមដានត្រួតពិនិត្យដំណើរការការដ្ឋានសាងសង់ លើកវិធានការចំពោះការសាងសង់រំលោភលើដីសាធារណៈ ការសាងសង់គ្មានលិខិតអនុញ្ញាត និងការសាងសង់ខុសពីលិខិតអនុញ្ញាត។

១៦-ឯកឧត្តម **ឡៅ ធិព្វសីហា** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី នាយកដ្ឋានសិក្សាគម្រោងប្លង់នៃអគ្គនាយកដ្ឋានសំណង់ ការងារមន្ទីរពិសោធន៍សំណង់ ការងារប្រមូលផ្តុំទិន្នន័យសំណង់ និងតាមដានត្រួតពិនិត្យដំណើរការការដ្ឋានសាងសង់ លើកវិធានការចំពោះការសាងសង់រំលោភលើដីសាធារណៈ ការសាងសង់គ្មានលិខិតអនុញ្ញាត និងការសាងសង់ខុសពីលិខិតអនុញ្ញាត។

១៧-ឯកឧត្តម **សៀក វណ្ណា** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី គណៈកម្មការសុរិយោដី ការងារនាយកដ្ឋានអភិរក្សសុរិយោដី ក្រុមការងារអភិវឌ្ឍនិងផ្សព្វផ្សាយ គោលនយោបាយនិងច្បាប់ និងជាតំណាងក្រសួងនៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីក្នុងករណីអវត្តមានឯកឧត្តមទេសរដ្ឋមន្ត្រី។

១៨-ឯកឧត្តម **អ៊ិត សុត្ថា** អនុរដ្ឋលេខាធិការ មានភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដោះស្រាយទំនាស់ដីធ្លី សុរិយោដីនិងភូមិសាស្ត្រ ការងារប្រព័ន្ធព័ត៌មានដីធ្លី ការកសាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ (NSDI) និងកិច្ចការព្រំដែន។

**ប្រការ ២** : រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មានភារកិច្ចអនុវត្តនូវការងារផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ ៣** : រាល់សេចក្តីសម្រេច និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤** : រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ គ្រប់អគ្គលេខាធិការ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាន នាយកដ្ឋាន អង្គភាពពាក់ព័ន្ធ គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ